# ពិធីធ្វើបុណ្យ ពុទ្ធាភិសេក

## ១). អត្ថបទពុទ្ធាភិសេក ជាអត្ថបទរបស់សម្តេចព្រះសង្ឃរាជ ជួន ណាត

♠ ខ្ញុំកូណា អាត្មាភាព បានសរសេរចម្លងតាមច្បាប់ដើម និងកែនូវអក្ខរាវិរុទ្ធបាលីភាសា ដែលមានការខុសខ្លះៗ ដើម្បីចងក្រងជាសៀវភៅ បុណ្យពុទ្ធាភិសេក ។

ឥឡូវនេះ ខ្ញុំកូណា អាត្មាភាព បានអានពិនិត្យមើលទៅឃើញថា មានលក្ខណៈត្រឹមត្រូវដ៏ល្អប្រសើរផង គឺសម្តេចព្រះមហាសុមេធាធិបតី ជួន ណាត ជោតញ្ញាណោ ព្រះសង្ឃរាជថ្នាក់ទី១ នៃគណៈមហានិកាយ បានរៀបរៀងនៅពាក់កណ្តាលសតវស្សទី២០ ។

ម្យ៉ាងវិញទៀត បណ្តាអត្ថបទនេះ ជាអត្ថបទដែលមានបែបឃ្លាឃ្លោងច្បាស់លាស់ ដ៏ត្រឹមត្រូវតាមព្រះពុទ្ធដីកា ទើបខ្ញុំកូណា អាត្មាភាព សរសេរនូវអត្ថបទនេះឡើង ដើម្បីដាក់ផ្សាយតាមអ៊ីនធឺណិត វត្តពោធិការាម នៃ ពុទ្ធិកសមាគមខេមរមណ្ឌល អូត្តាវ៉ា នឹងទុកចែកជាធម្មទានដល់ពុទ្ធបរិស័ទជិតឆ្ងាយទាំងឡាយ ដែលស្រឡាញ់រាប់អាននូវប្រពៃណី នៃវិស័យព្រះពុទ្ធសាសនាគ្រាន់និងបានចេះដឹងនូវរបៀបធ្វើបុណ្យពុទ្ធាភិសេកនេះ ។

អាស្រ័យដូចបានប្រគេន និងជំរាបជូនដល់វិទូកោវិទ្ទទាំងផ្នែកបព្វជិត ទាំងផ្នែកគ្រហស្ថ មេត្តាជួយកែសម្រួលនូវកំហុសឆ្គងទាំងឡាយ ដោយចេតនានិងអចេតនាតាមការគួរ ដើម្បីឱ្យអត្ថបទនេះមានសុពលភាពប្រសើរឡើង សំរាប់ចែកជូនដល់ប្រជាពលរដ្ឋខ្មែរទូទៅ ដែលជាអ្នកត្រូវកាចង់ចេះចង់ដឹងនូវរបៀបរបបប្រពៃណីជាតិខ្លួន ក៏ដូចជាវិស័យព្រះពុទ្ធសាសនាផងដែរ ។

សូមផ្សាយនូវបុញ្ញកុសលនេះ ជូនដល់ញាតកាទាំង៧សន្តាន និងវីរៈមហាបណ្ឌិតគ្រប់ជំនាន់ទាំងអស់ ដែលបានខិតខំស្រាវជ្រាវទុកនិងរៀបចំឡើង ដើម្បីកុលបុត្រកម្ពុជា ដោយបុញ្ញកម្មនេះ សូមឱ្យបានទៅកើតក្នុងសុគតិភព និងឱ្យបានរួចចាកទុក្ខភ័យ ដោយការឧទ្ទិសប្រគេននិងឧទ្ទិសជូននេះ សូមទទួលដោយសេចក្តីរីករាយ ។

សូមឱ្យសព្វសត្វទាំងអស់ក្នុងលោកនេះ មានសេចក្តីសុខនិងមានមេត្តាដល់គ្នានិងគ្នា កុំឱ្យមានការចងពៀរវេរាដល់គ្នា ព្រោះជាហេតុធ្វើឱ្យបាត់បង់នូវកុសលជាតិនិងអនាគតជាតិ ។

# របៀបធ្វើពិធី បុណ្យពុទ្ធាភិសេក

ការស្រោចស្រប់ រីជជុះរលាស់ ប្រោះព្រំនូវសុគន្ធវារីថ្វាយដល់ព្រះពុទ្ធរូប ដែលទើបកសាងថ្មី ហៅថា **ពុទ្ធាភិសេក** ។ ពិធីនេះជាប្រពៃណី ដែលពុទ្ធបរិស័ទបានធ្វើអស់កាលយូរអង្វែងមកហើយ និងជាប់មានដរាបមកដល់សម័យយើងសព្វថ្ងៃនេះ ។

បណ្ឌិតអ្នកប្រាជ្ញពុទ្ធសាសនិកទាំងឡាយ មានព្រះនាគសេនមហាថេរជាដើម បានធ្វើតាមលំអានរឿង ដែលព្រះមហាបុរស សិទ្ធត្ថសក្យមុនីគោតម ទ្រង់បានត្រាស់ដឹងនូវអនុត្តរសម្មាសម្ពោធិ បានដល់នូវឋានៈជាព្រះអរហន្តសម្មាសម្ពុទ្ធប្រាកដឡើង នៅពេលខាងចុងបច្ឆិមយាមនៃរាត្រី ពេញបូរណ៌មី ខែពិសាខនោះ គ្រាន់តែព្រះអង្គបានផ្ចាញ់មារហើយ និងបានត្រាស់ជាព្រះសម្ពុទ្ធភ្លាម ក៏កើតមានអព្ភូតហេតុជាមហាអស្ចារ្យ មានទេវតា ព្រះឥន្ទ ព្រះព្រហ្មទាំងឡាយ និមិត្តខ្លួនតូចៗល្អិតៗ មកប្រជ្រៀតគ្នាណែនណាន់តាន់តាប់ បន្លឺវាចាអឺងអាប់ថ្វាយពរថ្វាយជ័យ ចំពោះព្រះសម្មាសម្ពុទ្ធថា ព្រះពុទ្ធមានសិរី ទ្រង់ឈ្នះហើយ! មារមានចិត្តបាបចាញ់ព្រះអង្គហើយ! មិនត្រឹមតែបន្លឺនូវឧគ្ឃោសន វាចាថ្វាយពរថ្វាយជ័យប៉ុណ្ណោះទេ, ពួកទេវតា ឥន្ទ ព្រហ្មទាំងនោះ ថែមទាំងបាចសាចសុគន្ធបុប្ផាទិព្វ ប្រោះព្រំនូវសុគន្ធវារីទិព្វ មានគន្ធព្វទេវតាទាំងឡាយ ប្រគុំតូរ្យតន្ត្រីទិព្វថ្វាយពរថ្វាយជ័យ ចំពោះព្រះសម្មាសម្ពុទ្ធផងទៀត ដោយអំណាចដ៏ក្រៃលែង ។

ព្រះមហាបុរសទ្រង់បានត្រាស់ជាព្រះអរហន្តសម្ពុទ្ធរួចស្រេចហើយយ៉ាងនេះ ទើបអទិស្សមានកាយទាំងឡាយ មានទេវតាជាដើម បាននាំគ្នាមូលមកសម្តែងសេចក្តីគោរពចំពោះព្រះអង្គ ។ ព្រោះហេតុនេះឯង បានជាពិធីនេះឈ្មោះថា ពុទ្ធាភិសេក គឺការបាចសាចប្រោះព្រំ នូវសុគន្ធបុប្ផានឹងសុគន្ធវារីទិព្វ ថ្វាយស័ព្ទសាធុការពរជ័យសិរីមង្គលចំពោះព្រះអង្គ ។ ដោយមានសោមនស្សចិត្តនឹងមានសេចក្តីជ្រះថ្លាក្រៃលែងនៃពពួកអទិស្សមានកាយ មានទេវតាជាដើម បន្ទាប់ពីវេលាដែលព្រះអង្គបានត្រាស់ជាព្រះពុទ្ធរួចស្រេចហើយ ពុំមែនព្រះអង្គបានត្រាស់ជាព្រះសម្មាសម្ពុទ្ធនោះ ដោយសារពពួកអទិស្សមានកាយថ្វាយព្រះអង្គទេ ។ ព្រោះហេតុនោះហើយ បានជាព្រះពុទ្ធទ្រង់មានព្រះ **នេមិត្តិកនាម** ថា **សម្មាសម្ពុទ្ធោ** ដែលមានអត្ថន័យថា " ព្រះអង្គត្រាស់ដឹងដោយប្រពៃ នូវញេយ្យធម៌ទាំងពួង ដោយព្រះអង្គឯង ឥតមានទេវតា ឥន្ទ ព្រហ្ម ឬមនុស្សណាធ្វើឱ្យព្រះអង្គបានត្រាស់ដឹងឡើយ " ។

ដោយមានរឿងនេះជាមូលហេតុ ទើបពុទ្ធបរិស័ទគ្រប់មជ្ឈដ្ឋានទាំងឡាយ បានរៀបចំធ្វើពិធីបុណ្យពុទ្ធាភិសេកនេះឡើង ។ ពិធីនេះ ពុំមែនសុទ្ធតែដូចគ្នាតែបែបមួយនោះទេគឺពុទ្ធសាសនិកជនខ្លះ

ធ្វើដោយពិធីពិស្តារ ខ្លះធ្វើដោយពិធីជាមធ្យម ខ្លះធ្វើដោយពិធីសង្ខេប តាមយោបល់នឹងការលៃលក កុំឱ្យតែខានពុំបានធ្វើពិធីនោះ ព្រោះគេជឿជាក់ថា ព្រះពុទ្ធរូបដែលគេបានកសាងថ្មីនេះ ទុកស្មើដូចអង្គព្រះពុទ្ធដែលទើបបានត្រាស់ដឹងនូវអនុត្តរសម្មាសម្ពោធិថ្មីៗ គេគ្រាន់តែធ្វើពិធីអភិសេក រំលឹកតាមលំអានរឿងនោះ កុំឱ្យតែខានធ្វើសោះ ដើម្បីឱ្យបានផលានិសង្សជាថ្មីថែមឡើងទៀត ។

១). **ពិធីពុទ្ធាភិសេកពិស្តារ** នៅប្រទេសកម្ពុជា មានពណ៌នាក្នុងក្បួនបុរាណស្រាប់ហើយ មិនបាច់ថ្លែងនោះទេ ការគួរធ្វើដោយសព្វគ្រប់តាមរបៀបបុរាណ នឹងការមិនគួរធ្វើត្រង់ពិធីណានោះ គួរពុទ្ធបរិស័ទពិចារណារិះរកឱ្យបានហ្មត់ចត់វែងឆ្ងាយ ដើម្បីឱ្យឃើញតាមការណ៍ពិតនិងការណ៍មិនពិត ។ ក្នុងពិធីពុទ្ធាភិសេកពិស្តារនោះ មានពុទ្ធសាសនិកជនបរទេសខ្លះ គេធ្វើឱ្យត្រូវត្រង់ថ្ងៃ១៤កើត និងថ្ងៃ១៥កើត ខែពិសាខ តាមតែក្នុងឆ្នាំណាក៏ដោយ ។ នៅថ្ងៃ១៤កើត គេរៀបចំគ្រឿងសក្ការបូជាថ្វាយព្រះពុទ្ធរូបអង្គថ្មី តាំងពីពេលព្រលប់រហូតដល់ភ្លឺ គេធ្វើពិធីចំអិនមធុបាយាស ដែលហៅថា និរុទកមធុបាយាស គឺមធុបាយាសគោក គួរពូតជាពុំនូតបាន ។

ថ្វាយព្រះពុទ្ធរូបអង្គថ្មី នៅពេលព្រឹកព្រលឹមនៃថ្ងៃ១៥កើត គឺជាថ្ងៃពេញបូណ៌មី ខែពិសាខ ឱ្យត្រូវតាមលំអានរឿងនៃនាងសុជាតា ដែលថ្វាយមធុបាយាស ចំពោះព្រះសិទ្ធត្ថ សក្យមុនីគោតម ។ នៅថ្ងៃ១៥កើត ខែពិសាខនោះ តាំងពីពេលព្រលប់រហូតដល់ភ្លឺ ជាពិធីពុទ្ធាភិសេក នឹងបញ្ចប់ពិធីនេះនៅពេលព្រឹកនៃថ្ងៃ១រោច ។

២). **ពិធីពុទ្ធាភិសេកមធ្យម** គឺពិធីយ៉ាងកណ្តាល មិនវែងមិនខ្លីពេក ។ តាមប្រពៃណីឬទំលាប់ក្នុងប្រទេសកម្ពុជាយើង ទោះនៅថ្ងៃ ខែឆ្នាំណាក៏ដោយ ពុទ្ធបរិស័ទតែងធ្វើពិធី ពុទ្ធាភិសេក មានរបៀបជារយៈមាន ៩ សង្កាត់គឺៈ

- ទី១ រៀបចំគ្រឿងសក្ការៈបូជាមានផ្កាស្រស់ៗនឹងទៀនធូបជាដើម ថ្វាយព្រះពុទ្ធរូបអង្គថ្មី ។
- ទី២ និមន្តព្រះភិក្ខុសង្ឃចម្រើននូវព្រះបរិត្ត ។
- ទី៣ និមន្តព្រះធម្មកថិកមួយអង្គសម្តែងរឿងបឋមត្រាស់ ។
- ទី៤ និមន្តព្រះភិក្ខុមួយអង្គ ឬពីរអង្គសូត្របាលីពុទ្ធាភិសេក ។
- ទី៥ សូត្របទ ធម្មប្បដិយោគ ដែលធ្លាប់ហៅថា ធម៌យ៉ោគ ។
- ទី៦ សូត្របទផ្ចាញ់មារ ។
- ទី៧ និមន្តព្រះភិក្ខុសង្ឃសូត្រនូវបាលីគាថា ពុទ្ធជយមង្គល គឺធម៌ ពាហុំ ។ បេ ។

អជិតមេយ្យ ជហេ សបញ្ញោ ។ រួចសូត្រធម៌ មហាការុណិកោ ជាថោ ។ បេ ។ ហោតុ តេ ជយមង្គលំ ។ សូត្រធម៌ ជយន្តោ ពោធិយា មូលេ ។ បេ ។ លភន្តត្ថេ បទក្ខិណេ, រួចសូត្រ តេ អត្ថលទ្ធា សុខិតា ។ បេ ។ សហ សព្វេហិ ញាតិភិ ។ បន្ទាប់ពីនេះ ជួនកាលក៏សូត្រធម៌ ភវតុ សព្វមង្គលំ ។ បេ ។ សព្វសង្ឃានុភាវេន សទា សោត្ថី ភវន្តុ តេ ។

- ទី៨ ពុទ្ធបរិស័ទបាចសាចផ្កាស្រស់ៗមានផ្កាម្លិះជាដើម ទៅលើព្រះពុទ្ធរូបអង្គថ្មី អ្នកខ្លះមានសុគន្ធវារី ក៏ជជុះរលាស់ទឹកក្រអូបនោះថ្វាយព្រះពុទ្ធរូបអង្គថ្មី ដោយស្ងៀមឥតមានបញ្ចេញវាចាថាអ្វី ជួនកាលកំពុងធ្វើពិធីនេះ អាចារ្យម្នាក់បានបញ្ចេញវាចាឮខ្លាំងៗឱ្យពុទ្ធបរិស័ទថាតាមទាំងអស់គ្នាថា "ព្រះពុទ្ធមានសិរីទ្រង់ឈ្នះហើយ! មារមានចិត្តបាបចាញ់ព្រះអង្គហើយ!" (៣ដង) ។

- ទី៩ លុះចប់ពិធីនេះ ពុទ្ធបរិស័ទដែលជា ឧបាសក ឧបាសិកា ទាំងអស់គ្នាសូត្រធម៌នមស្សការព្រះរតនត្រ័យ ទៅតាមទំលាប់ដែលធ្លាប់សូត្ររៀងមក រួចហើយសូត្រធម៌ឧទ្ទិសកុសលផលបុណ្យដូចសព្វដង ទើបសន្មតិថាចប់ ពិធីបុណ្យពុទ្ធាភិសេកមធ្យមត្រឹមតែប៉ុណ្ណេះ ។

៣). **ពិធីពុទ្ធាភិសេកសង្ខេប** ជាពិធីខ្លីៗបានរៀបរៀងពិធីនេះ ទុកជារបៀបឱ្យពុទ្ធបរិស័ទអ្នកត្រូវការធ្វើពិធីពុទ្ធាភិសេកសង្ខេប ។ ពិធីសង្ខេបនេះ មានត្រឹមតែការរៀបចំតាក់តែងគ្រឿងសក្ការៈបូជាដោយផ្កាស្រស់ៗនិងទៀនធូបថ្វាយព្រះពុទ្ធរូបអង្គថ្មីប៉ុណ្ណោះ រួចហើយត្រូវនិមន្តព្រះធម្មកថិកមកសម្តែងនូវរឿងបឋមត្រាស់ តាមសមគួរដល់ពេលវេលា ឬមិនបាច់មានទេសនាបឋមត្រាស់ក៏បាន មិនបាច់មានការសូត្របាលី ពុទ្ធាភិសេកក៏បាន ។ និមន្តព្រះភិក្ខុសង្ឃ៤អង្គ ឬច្រើនអង្គជាងនេះក៏បាន ហើយអារាធនាលោកឱ្យស្វាធ្យាយធម៌សម្រាប់សូត្រ ពុទ្ធាភិសេក តាមលំដាប់ពិធីនោះ ។

នៅទីចប់បាលីទាំងអស់ មានប្រែជាសម្រាយតាមសេចក្តីលំអានបាលី សម្រាប់ឱ្យដឹងដំណើររឿងនៃបុណ្យពុទ្ធាភិសេកសង្ខេបនេះ ។ ព្រះភិក្ខុសង្ឃត្រូវការសូត្រនូវសម្រាយនោះផងក៏បាន មិនបាច់សូត្រសម្រាយក៏បាន ព្រោះសម្រាយនៅខាងចុង ដោយមានវគ្គលេខរៀងតាមលំដាប់ខាងក្រោម ។

## ព្រះភិក្ខុសង្ឃស្វាធ្យាយដូចតទៅ

១). នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

២). តស្មឹ សមយេ ពោធិសត្តោ ពោធិរុក្ខក្ខន្ធំ បិដ្ឋិតោ កត្វា បុរត្ថាភិមុខោ ទឡ្ហមានសោ ហុត្វា,

ភាមំ តចោ នហារុ ច អដ្ឋិ ច អវសិស្សតុ សព្វំបិ ហិទំ សរីរេ មំសលោហិតំ ឧបសុស្សតុ ឥធេវ សម្មាសម្ពោធឹ អប្បត្វា ឥមំ បល្លង្កំ ន ភិន្ទិស្សាមីតិ អសនិសតសន្និបាតេនាបិ អភេជ្ជរូបំ អបរាជិតំ បល្លង្កំ អាភុជិត្វា និសីទិ ។

៣). តតោ មហាបុរិសោ អនុលោមប្បដិលោមំ បដិច្ចសមុប្បាទំ មនសាកាសិ,

អវិជ្ជា បច្ចយា សង្ខារា, សង្ខារប្បច្ចយា វិញ្ញាណំ, វញ្ញាណប្បច្ចយា នាមរូបំ, នាមរូបប្បច្ចយា សឡាយតនំ, សឡាយតនប្បច្ចយា ផស្សោ, ផស្សប្បច្ចយា វេទនា, វេទនាបច្ចយា តណ្ហា, តណ្ហាបច្ចយា ឧបាទានំ, ឧបាទានប្បច្ចយា ភវោ, ភវប្បច្ចយា ជាតិ, ជាតិប្បច្ចយា ជរាមរណំ, សោកបរិទេវទុក្ខទោមនស្សុបាយាសា សម្ភវន្តិ, ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស សមុទយោ ហោតិ ។

៤). អវិជ្ជាយត្វេវ អសេសវិរាគនិរោធា, សង្ខារនិរោធោ សង្ខារនិរោធា, វិញ្ញាណនិរោធោ វិញ្ញាណនិរោធា, នាមរូបនិរោធោ នាមរូបនិរោធា, សឡាយតននិរោធោ សឡាយតននិរោធា, ផស្សនិរោធោ ផស្សនិរោធា, វេទនានិរោធោ វេទនានិរោធា, តណ្ហានិរោធោ តណ្ហានិរោធា, ឧបាទាននិរោធោ ឧបាទាននិរោធា

ភវនិរោធោ ភវនិរោធា, ជាតិនិរោធោ ជាតិនិរោធា, ជរាមរណំ សោកបរិទេវទុក្ខទោមនស្សុបាយាសា និរុជ្ឈន្តិ, ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស និរោធោ ហោតិ ។

៥). មហាបុរិសោ ឯតមត្ថំ វិទិត្វា តទនន្តរេ យថាក្កមំ តយោ វារេ ឧទានានិ ឧទានេសិ,

យទា ហវេ បាតុភវន្តិ ធម្មា អាតាបិនោ
ឈាយតោ ព្រាហ្មណស្ស អថស្ស កង្ខា
វបយន្តិ សព្វា យតោ បជានាតិ សហេតុធម្មន្តិ ។

៦). យទា ហវេ បាតុភវន្តិ ធម្មា អាតាបិនោ
ឈាយតោ ព្រាហ្មណស្ស អថស្ស កង្ខា
វបយន្តិ សព្វា យតោ ខយំ បច្ចយានំ អវេទីតិ ។

៧). យទា ហវេ បាតុភវន្តិ ធម្មា អាតាបិនោ
ឈាយតោ ព្រាហ្មណស្ស វិធូបយំ តិដ្ឋតិ
មារសេនំ សុរិយោវ ឱភាសយមន្តលិក្ខន្តិ ។

៨). យតោ មហាបុរិសោ បូរិតបារមីនំ ពោធិសត្តានំ អភិសម្ពុជ្ឈនទិវសេ បល្លង្កោ មយ្ហំ បាបុណាតីតិ វត្វា ឋិតំ មារំ អាហ មារ តុយ្ហំ ទានស្ស ទិន្នភាវេ កោ សក្ខីតិ ។

៩). មារោ ឥមេ ឯត្តកា សក្ខិនោតិ មារគណាភិមុខំ ហត្ថំ បសារេសិ ។

១០). តស្មឹ ខណេ មារបរិសាយ អហំ សក្ខី អហំ សក្ខីតិ បវត្តសទ្ទោ បឋវីឧទ្រិយនសទ្ទសទិសោ អហោសិ ។

១១). អថ មារោ មហាបុរិសំ អាហ សិទ្ធត្ថ តុយ្ហំ ទានស្ស ទិន្នភាវេ កោ សក្ខីតិ ។

១២). មហាបុរិសោ តុយ្ហំ តាវ ទានស្ស ទិន្នភាវេ សចេតនា សក្ខិនោ មយ្ហំ បន ឥមស្មឹ ឋានេ សចេតនោ កោចិ សក្ខី នាម នត្ថិ តិដ្ឋតុ តាវ មេ អវសេសត្តភាវេសុ ទិន្នទានំ វេស្សន្តរត្តភាវេ បន ឋត្វា សត្តសតកមហាទានស្ស តាវ ទិន្នភាវេ អយំ អចេតនាបិ មហាបថវី សក្ខីតិ ចីវរគព្ភន្តរតោ ទក្ខិណាហត្ថំ អភិនីហរិត្វា វេស្សន្តរត្តភាវេ ឋត្វា មយ្ហំ សត្តសតកមហាទានស្ស ទិន្នភាវេ ត្វំ សក្ខី ន សក្ខីតិ មហាបថវ្យាភិមុខំ ហត្ថំ បសារេសិ ។

១៣). មហាបថវី អហន្តេ តទា សក្ខីតិ វិរាវសតេន វិរាវសហស្សេន មារពលំ អវត្ថរមានា វិយ ឧន្នាទិនី អហោសិ ។

១៤). តតោ មហាបថវី ទិន្នន្តេ សិទ្ធត្ថ មហាទានំ ឧត្តមទានន្តិ ។

១៥). វេស្សន្តរត្តភាវេន ទិន្នទានំ សម្មសន្តេ សម្មសន្តេ ទិយឌ្ឍយោជនសតិកោ គិរិមេខលហត្ថី ជន្នុកេហិ បតិដ្ឋាសិ ។

១៦). មារបរិសា ទិសាវិទិសា បលាយិ ។

១៧). ទ្វេ ឯកមគ្គេន គតា នាម នត្ថិ ។

១៨). សីសាភរណានិ ចេវ និវត្ថវសនានិ ច បហាយ សម្មុខសម្មុខា ទិសាហិយេវ បលាយឹសុ ។

១៩). តតោ ទេវសង្ឃា បលាយមានំ មារពលំ ទិស្វា មារស្ស បរាជយោ ជាតោ សិទ្ធត្ថមហាបុរិសស្ស ជយោ ជយបូជំ ករិស្សាមាតិ នាគា នាគានំ សុបណ្ណា សុបណ្ណានំ ទេវតា ទេវតានំ ព្រហ្មានោ

ព្រហ្មានំ ឧគ្ឃោសេត្វា វិជ្ជាធរា គន្ធមាលាទិហត្ថា មហាបុរិសស្ស សន្តិកំ ពោធិបល្លង្កំ អាគមឹសុ ។

២០). ឥច្ចេវំ បន វេទិតព្វំ,

♠ " ជយោ ហិ ពុទ្ធស្ស សិរីមតោ អយំ!
មារស្ស ច បាបិមតោ បរាជយោ!″
ឧគ្ឃោសយុំ ពោធិមណ្ឌេ បមោទិតា
ជយំ តទា នាគគណា មហេសិនោ ។

♠ " ជយោ ហិ ពុទ្ធស្ស សិរីមតោ អយំ!
មារស្ស ច បាបិមតោ បរាជយោ!″
ឧគ្ឃោសយុំ ពោធិមណ្ឌេ បមោទិតា
សុបណ្ណសង្ឃាបិ ជយំ មហេសិនោ ។

♠ " ជយោ ហិ ពុទ្ធស្ស សិរីមតោ អយំ!
មារស្ស ច បាបិមតោ បរាជយោ!″
ឧគ្ឃោសយុំ ពោធិមណ្ឌេ បមោទិតា
ជយំ តទា ទេវគណា មហេសិនោ ។

♠ " ជយោ ហិ ពុទ្ធស្ស សិរីមតោ អយំ!
មារស្ស ច បាបិមតោ បរាជយោ!″
ឧគ្ឃោសយុំ ពោធិមណ្ឌេ បមោទិតា
ជយំ តទា ព្រហ្មគណាបិ តាទិនោ ។

២១). មហាបុរិសោ បន ទសសហស្សីលោកធាតុំ ឧន្នាទេត្វា អរុណុគ្គមនវេលាយ សព្វញ្ញុតញ្ញាណំ បដិវិជ្ឈិ ។

២២). ឯវំ អបរិមាណេន សិរីវិភវេន បូជិយមានោ នានប្បការេសុ អច្ឆរិយធម្មេសុ បាតុភូតេសុ សព្វញ្ញុតំ បដិវិជ្ឈិត្វា សព្វពុទ្ធានំ អវិជ្ជហិតំ ឧទានំ ឧទានេសិ ។

២៣). អនេកជាតិសំសារំ សន្ធាវិស្សំ អនិព្វិសំ
គហការំ គវេសន្តោ ទុក្ខា ជាតិ បុនប្បុនំ
គហការក ទិដ្ឋោសិ បុនគេហំ ន កាហសិ
សព្វា តេ ផាសុកា ភគ្គា គហកូដំ វិសង្ខតំ
វិសង្ខារគតំ ចិត្តំ តណ្ហានំ ខយមជ្ឈគាតិ ។

# ប្រែជាសម្រាយ

**តាមលំដាប់លេខរៀងពីលេខ១ដល់លេខរៀងទី២៣ ដូចមានសេចក្តីប្រាប់ខាងក្រោមនេះគឺ៖**

១). វីកិរិយានមស្សការថ្វាយបង្គំ នៃខ្ញុំព្រះករុណា ចូរមានដល់ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គជាព្រះអរហន្តដ៏ប្រសើរ ទ្រង់ត្រាស់ដឹងនូវញេយ្យធម៌ទាំងពួង ដោយប្រពៃចំពោះព្រះអង្គ ឥតមានគ្រូអាចារ្យណាប្រដៅព្រះអង្គឡើយ ។

២). ក្នុងសម័យនោះ ព្រះពោធិសត្វទ្រង់បែរព្រះប្រឹងស្កាង្គ គឺខ្នងព្រះអង្គទៅរកដើមពោធិព្រឹក្ស ឆ្ពោះព្រះភក្ត្រទៅខាងទិសបូព៌ា ទ្រង់តាំងព្រះហឫទ័យយ៉ាងម៉ឹងម៉ាត់ថា " ស្បែកក្តី សរសៃក្តី ឆ្អឹងក្តី (បើត្រូវស្ងួតក្រៀម) ក៏ចូរស្ងួតក្រៀមចុះ ទោះសាច់និងឈាមទាំងអស់ក្នុងសរីរៈរាងកាយនេះ ក៏ដោយ (បើត្រូវរីងស្ងួត) ក៏ចូររីងស្ងួតទៅចុះ បើអាត្មាអញមិនបានដល់នូវសម្មាសម្ពោធិក្នុងទីនេះទេ អាត្មាអញនឹងមិនរំលាយរំសាយភ្នែននេះឡើយ" ព្រះអង្គពែននូវអបរាជិតបល្លង្ក គឺព្រះភ្នែនមានជ័យ មានសភាពនឹងធឹងដែលអ្នកណាមួយ ឬអ្វីមួយនឹងទំលាយមិនបានហើយ ទ្រង់គង់យ៉ាងនឹងធឹងឥតកម្រើក ប្រសិនបើ វន្ទះទាំងរយបាញ់ប្រជុំគ្នាមកក៏ព្រះអង្គឥតស្ទើបរំភើបឡើយ ។

៣). លំដាប់នោះ ព្រះមហាបុរស ទ្រង់រំពឹងពិចារណានូវបដិច្ចសមុប្បាទធម៌ ជាអនុលោមនិងបដិលោមថា សង្ខារទាំងឡាយកើតមានព្រោះអវិជ្ជាគឺមោហៈ ងងឹតល្ងង់ជាបច្ច័យឱ្យកើត, វិញ្ញាណកើតមាន ព្រោះសង្ខារជាបច្ច័យឱ្យកើត, នាមធម៌និងរូបធម៌កើតមាន ព្រោះវិញ្ញាណជាបច្ច័យឱ្យកើត,

អាយតនៈ៦កើតមាន ព្រោះនាមធម៌និងរូបធម៌ជាបច្ច័យឱ្យកើត, ផស្សៈកើតមាន ព្រោះអាយតនៈ៦ជាបច្ច័យឱ្យកើត, វេទនាកើតមាន ព្រោះផស្សៈជាបច្ច័យឱ្យកើត, តណ្ហាកើតមាន ព្រោះវេទនាជាបច្ច័យឱ្យកើត, ឧបាទានកើតមាន ព្រោះតណ្ហាជាបច្ច័យឱ្យកើត, ភពកើតមាន ព្រោះឧបាទានជាបច្ច័យឱ្យកើត, ជាតិគឺកំណើតកើតមាន ព្រោះភពជាបច្ច័យឱ្យកើត, ជរានិងមរណៈកើតមាន ព្រោះជាតិជាបច្ច័យឱ្យកើត, (កាលបើបដិច្ចសមុប្បាទជាសម្ភវធម៌ទាំង១២នេះនៅមាន), សេចក្តីសោកសៅ ស្តាយ អាលោះអាល័យ ការយំខ្សឹកខ្សួល សេចក្តីលំបាកកាយ ទោមនស្សតូចចិត្តនិងឧបាយាសៈគឺសេចក្តីចង្អៀតតានតឹងចិត្ត តែងតែកើតមានឡើងផងដែរ ។

ការកើតឡើងនៃកងទុក្ខទាំងអស់នេះ ចេះតែមាន (ព្រោះមានធម៌ជាបច្ច័យទាក់ទងគ្នានាំឱ្យកើតមាន) យ៉ាងនេះឯង (ពុំមានដទៃក្រៅពីនេះឡើយ) ។

៤). កាលបើអវិជ្ជារលត់សូន្យជាវិរាគធម៌ ឥតសេសសល់ហើយ សង្ខារក៏រលត់, សង្ខាររលត់ វិញ្ញាណក៏រលត់, វិញ្ញាណរលត់ នាមធម៌និងរូបធម៌ក៏រលត់, នាមធម៌និងរូបធម៌រលត់ អាយតនៈ៦ក៏រលត់, អាយតនៈ៦រលត់ ផស្សៈក៏រលត់, ផស្សៈរលត់ វេទនាក៏រលត់, វេទនារលត់ តណ្ហាក៏រលត់, តណ្ហារលត់ ឧបាទានក៏រលត់, ឧបាទានរលត់ ភពក៏រលត់, ភពរលត់ ជាតិក៏រលត់, ជាតិរលត់ ជរានិងមរណៈក៏រលត់, (កាលបើបដិច្ចសមុប្បាទធម៌ទាំង១២នោះជានិរោធធម៌រលត់អស់ហើយ), សេចក្តីសោកសៅ ស្តាយ អាលោះអាល័យ ការយំខ្សឹកខ្សួល សេចក្តីលំបាកកាយ ទោមនស្សតូចចិត្តនិងឧបាយាសៈ គឺសេចក្តីចង្អៀតតានតឹងក្នុងចិត្តក៏រលត់ផងដែរ ។

ការរលត់នៃកងទុក្ខទាំងអស់នេះ (តៗគ្នា ព្រោះអស់មានធម៌ជាបច្ច័យនាំឱ្យកើត តទៅទៀត) យ៉ាងនេះឯង (ពុំមែនដទៃក្រៅពីនេះឡើយ) ។

៥). ព្រះមហាបុរស ទ្រង់ជ្រាបនូវបដិច្ចសមុប្បាទធម៌នោះហើយ ព្រះអង្គបន្លឺនូវព្រះឧទានវាចាទាំងឡាយអស់វារៈ៣ដងផង តាមលំដាប់មុនក្រោយក្នុងចន្លោះនៃការរំពឹងពិចារណានូវបដិច្ចសមុប្បាទធម៌នោះថា កាលណា បើពោធិបក្ខិយធម៌ និងចតុរារិយសច្ចធម៌ទាំងឡាយ កើតមានប្រាកដដល់ខីណាសវៈព្រាហ្មណ៍ អ្នកមានព្យាយាមញុំាងកិលេសឱ្យក្តៅសព្វ អ្នកដុតបំផ្លាញនូវកិលេស កាលនោះឯងសេចក្តីសង្ស័យទាំងអស់នៃខីណាសវៈព្រាហ្មណ៍នោះ ក៏បាត់សូន្យអស់ទៅ ព្រោះខីណាសវៈព្រាហ្មណ៍ដឹងច្បាស់នូវធម៌ទាំងឡាយ គឺចតុរារិយសច្ចធម៌ មានទុក្ខសច្ចជាដើម ។

៦). កាលណា បើពោធិបក្ខិយធម៌ និងចតុរារិយសច្ចធម៌ទាំងឡាយ កើតមានប្រាកដដល់ខីណាសវៈព្រាហ្មណ៍ អ្នកមានព្យាយាមញុំាងកិលេសឱ្យក្តៅសព្វ អ្នកដុតបំផ្លាញកិលេសកាលនោះឯង

សេចក្ដីសង្ស័យទាំងអស់នៃខីណាសវៈព្រាហ្មណ៍នោះ ក៏បាត់សូន្យអស់ទៅ ព្រោះខីណាសវៈព្រាហ្មណ៍បានដឹងនូវការអស់ទៅនៃធម៌ជាបច្ច័យទាំងឡាយ ។

៧). កាលណា បើពោធិបក្ខិយធម៌ និងចតុរារិយសច្ចធម៌ទាំងឡាយ កើតមានប្រាកដដល់ខីណាសវៈព្រាហ្មណ៍នោះ អ្នកមានព្យាយាមញុំាងនូវកិលេសឱ្យក្ដៅសព្វ ជាអ្នកដុតបំផ្លាញនូវកិលេស (កាលនោះឯង ខីណាសវៈព្រាហ្មណ៍នោះ) បានកំចាត់នូវពួកមារនិងសេនារបស់មារបាន (ក៏ភ្លឺស្វាង) ដូចជាព្រះអាទិត្យញុំាងអាកាសឱ្យភ្លឺច្បាស់ដូចនោះឯង ។

( **យទា ហវេ** ទាំង៣គាថានេះ ជាព្រះឧទានវាចានៃមហាបុរស ។ ក្នុងគម្ពីរបានប្រាប់នូវសេចក្ដីនេះថា ព្រះមហាបុរសទ្រង់បានបន្លឺនូវឧទានវាចានេះ ក្នុងចន្លោះនិងចន្លោះនៃការពិចារណានូវបដិច្ចសមុប្បាទធម៌ជាអនុលោម និងបដិលោម សាចុះ សាឡើងច្រើនដង ច្រើនសា ។

♠ ដោយហេតុនេះ បើពុទ្ធបរិស័ទអ្នកធ្វើពិធី ពុទ្ធាភិសេកសង្ខេប មិនគិតពីពេលវែងខ្លីទេ គួរនិមន្តព្រះសង្ឃឱ្យលោកស្វាធ្យាយបាលីបដិច្ចសមុប្បាទធម៌១ចប់ រួចស្វាធ្យាយបាលីគាថាតទៅទៀត គឺៈ

**យទា ហវេ បាតុភវន្តិ ធម្មា** ។ បេ ។ **យតោ បជានាតិ សហេតុធម្មំ** ។ រួចស្វាធ្យាយបាលីបដិច្ចសមុប្បាទធម៌១ចប់ទៀត ហើយស្វាធ្យាយ **យទា ហវេ បាតុភវន្តិ ធម្មា** ។ បេ ។ **យតោ ខយំ បច្ចយានំ អវេទី** ។ រួចស្វាធ្យាយបាលីបដិច្ចសមុប្បាទធម៌១ចប់ទៀត, ហើយស្វាធ្យាយ **យទា ហវេ បាតុភវន្តិ ធម្មា** ។ បេ ។ **សុរិយោវ ឱភាសយមន្តលិក្ខំ** ។ បើស្វាធ្យាយតាមន័យនេះ ឃើញថាស្វាធ្យាយបាលីបដិច្ចសមុប្បាទធម៌៣ចប់ **យទា ហវេ** ក៏៣ចប់ផងដែរ គឺស្វាធ្យាយឆ្លាស់គ្នាក្នុងចន្លោះៗ ) ។

៨). គ្រានោះ ព្រះមហាបុរសទ្រង់មានព្រះបន្ទូលថា " បល្ល័ង្ក (ដែលកើតឡើង) ក្នុងថ្ងៃនៃការត្រាស់ដឹងនៃពោធិសត្វទាំងឡាយ ដែលបានបំពេញបារមីហើយត្រូវបានមកតថាគត " ព្រះអង្គមានព្រះបន្ទូលទៅរកទេវបុត្រមារដែលឋិតនៅក្នុងទីនោះថា " នៃមារ! អ្នកណា ជាសាក្សីក្នុងភាវៈនៃទាន ដែលអ្នកឯងបានឱ្យហើយនោះ? " ។

៩). ទេវបុត្រមារ បានលាដៃឡើងចង្អុលអាងទៅរកពួករេហ៍ពលថា " ពពួករេហ៍ពលទាំងអម្បាលនេះ សុទ្ធតែជាសាក្សី " ។

១០). ខណៈនោះ សូរស័ព្ទសំដីនៃមារបរិស័ទ ក៏លាន់ឮកងរំពងឡើងថា ខ្ញុំជាសាក្សី! ខ្ញុំជាសាក្សី សូរស័ព្ទនោះហាក់ដូចជាស្រុតចុះនៃមហាប្រឹថពី ។

១១). លំដាប់នោះ ទេវបុត្រមារបានសួរទៅព្រះមហាបុរសថា នែ! សិទ្ធត្ថ អ្នកណាជាសាក្សីក្នុងភាវៈនៃទាន ដែលអ្នកឯងបានឱ្យហើយ? ។

១២). ព្រះមហាបុរសទ្រង់ឆ្លើយថា អ្នកឯងមានសាក្សី ដែលមានចេតនា ក្នុងភាវៈនៃទាន ដែលអ្នកឯងបានឱ្យហើយ ចំណែកខាងយើងក្នុងទីនេះ ឥតមានអ្នកណាមួយ ដែលមានចេតនាជាសាក្សីឱ្យយើងទេ ទានដែលយើងឱ្យហើយក្នុងអត្តភាពដ៏ពិសេសទាំងឡាយ ចូរលើកទុកចុះកុំបាច់យកមកនិយាយអាងឡើយ និយាយតែត្រឹម សត្តសតកៈមហាទាន ដែលកាលយើងស្ថិតនៅក្នុងអត្តភាពជាស្តេចវេស្សន្តរ ប៉ុណ្ណោះក៏បានហើយ មហាប្រឹថពីដែលគ្មានចេតនានេះ ជាសាក្សីរបស់យើង លុះព្រះអង្គឆ្លើយតបយ៉ាងនេះហើយ ទ្រង់បញ្ចេញព្រះហស្តខាងស្តាំពីក្នុងចន្លោះផ្ទៃនៃចីពរ ដែលព្រះអង្គឃ្លុំស្រេចស្រាប់ពីនាយមក ទ្រង់សំយុងព្រះហស្តចង្អុលឆ្ពោះទៅតាមមហាប្រឹថពី ដោយបញ្ជាក់ថា កាលដែលយើងឋិតនៅក្នុងអត្តភាពជា **ស្តេចមហាវេស្សន្តរ** យើងបានឱ្យ **សត្តសតកៈមហាទាន** តើមហាប្រឹថពីឯងជាសាក្សីមែនឬទេ? ។

១៣). មហាប្រឹថពីបានបញ្ចេញសូរស័ព្ទលាន់ឮខ្ទរខ្លាំងៗ ហាក់ដូចជាសន្ទាប់គំរាមរេហ៍ពលមារ ដោយសម្រែកសន្ធាប់រាប់រយរាប់ពាន់ឡើងថា ក្នុងកាលនោះ ខ្ញុំម្ចាស់ជាសាក្សីរបស់ព្រះអង្គ! ។

មហាប្រឹថពីនេះ បញ្ចេញសូរស័ព្ទដោយសម្តែងអាការៈជាស្រី ដោយហេតុនេះឯង បានជាបោរាណាចារ្យ ហៅមហាប្រឹថពី ដែលមានសភាពអស្ចារ្យ ក្នុងគ្រាឆ្លើយអាងជាសាក្សីនៃមហាបុរសនោះថា " នាងធរណី " អ្នកខ្លះ ហៅតាមទំលាប់តៗគ្នាមកថា " នាងគង្ហីងព្រះធរណី " ។

១៤). មិនត្រឹមតែបញ្ចេញសំអាងជាសាក្សីប៉ុណ្ណោះទេ មហាប្រឹថពីថែមទាំងឆ្លើយឡើងទៀតថា បពិត្រព្រះសិទ្ធត្ថ មហាទានដែលព្រះអង្គបានឱ្យហើយជាទានដ៏ឧត្តម ។

១៥). កាលដែលមហាបុរស ទ្រង់ពិចារណាហើយពិចារណាទៀតជារឿយៗ នូវទានកាលដែលព្រះអង្គនូវជា ស្តេចមហាវេស្សន្តរ ទ្រង់បានឱ្យជាមហាទានដ៏ឧត្តមនោះ ក៏ស្រាប់តែដំរីឈ្មោះ **គិរីមេខលៈ** មានកំពស់១៥០យោជន៍ ជាជំនិះទេវបុត្រមារនោះ ស្លុតលុតជង្គងចុះចាញ់បារមីទាននៃព្រះអង្គ ។

១៦). មារបរិស័ទ គឺពួករេហ៍ពលរបស់ទេវបុត្តមារ ក៏រត់ប្រសាចទៅតាមទិសទីទៃៗពីគ្នា ។

១៧). ពីរនាក់រត់ទៅតាមផ្លូវជាមួយគ្នាពុំមានសោះឡើយគឺរត់ទៅតាមផ្លូវដោយខ្លួនៗពីគ្នា ។

១៨). រេហ៍ពលមារទាំងនោះ បោះបង់គ្រឿងប្រដាប់ដែលពាក់នៅក្បាល និងគ្រឿងស្លៀកពាក់ រត់ទៅតាមទិសទីទាំងឡាយ ដែលចំមុខរៀងៗខ្លួន ។

១៩). លំដាប់នោះ ពួកទេវតាទាំងឡាយ បានឃើញរេហ៍ពលមារកំពុងរត់ប្រសាច ដូចនោះ ក៏ដឹងច្បាស់ថា បរាជ័យបានទៅទេវបុត្តមារ, ឯជ័យជំនះត្រូវបានមកព្រះសិទ្ធត្ថមហាបុរស ពួកយើងនិងទៅធ្វើជយបូជា ចំពោះព្រះអង្គហើយ បញ្ចេញឧគ្ឃោសនាករឮខ្លាំងៗកងរំពងឡើង គឺពួកនាគ ស្រែកប្រាប់នាគផងគ្នា, ពួកគ្រុឌ ស្រែកប្រាប់គ្រុឌផងគ្នា, ពួកទេវតា ស្រែកប្រាប់ទេវតាផងគ្នា, ពួកព្រហ្ម ស្រែកប្រាប់ព្រហ្មផងគ្នា, ពួកពិទ្យាធរ ស្រែកប្រាប់ពិទ្យាធរផងគ្នា, សុទ្ធតែមានហត្ថកាន់គ្រឿងបូជា មានគន្ធមាលាជាដើម មូលគ្នាមកកាន់ពោធិបល្ល័ង្កជិតជុំវិញមហាបុរស ។

២០). ពួកពុទ្ធបរិស័ទជ្រាបថា នៅពេលដែលទេវនិយាយមូលមកស្រែកទ្រហឹងអឺងកងថ្វាយពរ ថ្វាយជ័យបូជាចំពោះព្រះមហាបុរសនោះ ព្រះអដ្ឋកថាចារ្យលោកចងក្រងបាលី៤គាថានេះ សម្រាប់ស្វាធ្យាយក្នុងពិធីពុទ្ធាភិសេក រម្លឹកដល់រឿងដែលព្រះមហាបុរស បានសម្រេចអនុត្តរសម្មាសម្ពោធិ ។

**ជយោ ហិ ពុទ្ធស្ស សិរីមតោ អយំ**!, **មារស្ស ច បាបិមតោ បរាជយោ**! ព្រះពុទ្ធមានសិរីទ្រង់ឈ្នះហើយ! មារមានចិត្តបាបចាញ់ព្រះអង្គហើយ! (សម្រាប់ឱ្យពុទ្ធបរិស័ទបន្លឺ ជយឃោសនេះ ថ្វាយសាធុការពរ ចំពោះព្រះពុទ្ធរូបអង្គថ្មី ក្នុងពិធីធ្វើពុទ្ធាភិសេក) ។

២១). ឯព្រះមហាបុរសទ្រង់ញ៉ាំងលោកធាតុទាំង១ម៉ឺន ឱ្យកម្រើករំពើបហើយ លុះដល់វេលាអរុណជិតរះនៃថ្ងៃ១រោច ខែពិសាខ ព្រះអង្គក៏បានត្រាស់ដឹងនូវព្រះសព្វញ្ញុតញ្ញាណនេះឡើង ។

២២). ព្រះសព្វញ្ញុពុទ្ធ កាលដែលទេវនិយាយថ្វាយជយឃោស និងគ្រឿងបូជាដោយសិរីវិភព គឺសម្បត្តិសិរីប្រមាណពុំបានយ៉ាងនេះ កាលដែលអច្ឆរិយធម៌ទាំងឡាយ មានប្រការផ្សេងៗ កើតមានប្រកដឡើងហើយ ព្រះអង្គក៏បានត្រាស់ដឹងនូវសព្វញ្ញុតញ្ញាណហើយ ទ្រង់បន្លឺនូវព្រះឧទានវាចាដែលព្រះពុទ្ធគ្រប់ព្រះអង្គ (ទើបបានត្រាស់ភ្លាមៗ) ទ្រង់ពុំដែលបោះបង់គឺព្រះអង្គពុំដែលខានបន្លឺឡើយ ។

២៣). ព្រះអង្គទ្រង់បន្លឺនូវព្រះឧទានវាចាដូច្នេះថា៖ កាលដែលតថាគត កំពុងស្វែងរកជាងឈើ គឺតណ្ហាជាអ្នកធ្វើនូវផ្ទះគឺអត្តភាពរបស់តថាគត កាលដែលមិនទាន់បានជួបប្រទះនៅឡើយ តថាគត តែងតែអន្ទោលទៅកាន់សង្សារវដ្តរាប់ជាតិ ជាអនេក (ម្លោះហើយ) ជាតិក៏តែងតែនាំសេចក្តីទុក្ខមកឱ្យ តថាគតរឿយៗ ឥតស្រាកស្រាន្តឡើយ, នែជាងផ្ទះ ឥឡូវនេះ តថាគត រកអ្នកឃើញហើយណ៎ា!, ពីនេះតទៅ អ្នកឯងអស់ធ្វើផ្ទះគឺអត្តភាពឱ្យតថាគត បានទៀតហើយ បង្កង់គឺកិលេសដ៏សេសទាំងឡាយរបស់អ្នកឯង តថាគតបានកាច់បំបាក់អស់ទៅហើយ ទាំងកំពូលផ្ទះគឺអវិជ្ជា ដែលអ្នកឯងធ្វើរួចហើយ (នោះ) តថាគត ក៏បានកំចាត់បង់ហើយ ឥឡូវនេះ ចិត្តរបស់តថាគតបានដល់ព្រះនិព្វាន ដែលបានប្រាសចាកសង្ខារហើយ តថាគតបានត្រាស់ដឹងនូវព្រះអរហត្តដែលជាធម៌ក្ស័យទៅនៃតណ្ហាទាំងឡាយ ចាប់ពីពេលនេះទៅអ្នកឯងលែងបានបញ្ញានូវតថាគតតទៅទៀតហើយ ។

លុះព្រះភិក្ខុសង្ឃស្វាធ្យាយបាលីឧទានគាថានេះចប់ហើយ លោកអាចារ្យផ្នែកខាងគ្រហស្ថម្នាក់ បានសូត្រឱ្យអ្នកទាំងអស់គ្នាថាតាមព្រមៗដូច្នេះថា៖

**ជយោ ហិ ពុទ្ធស្ស សិរីមតោ អយំ**! " ព្រះពុទ្ធមានសិរីទ្រង់ឈ្នះហើយ! ",

**មារស្ស ច បាបិមតោ បរាជយោ**! " មារមានចិត្តបាបចាញ់ព្រះអង្គហើយ! " ។

សូត្រតាមអាចារ្យឱ្យព្រមៗគ្នា ឱ្យបានគ្រប់៣ដង, សូត្របណ្តើរ បាចសាចគន្ធបូជាថ្វាយព្រះពុទ្ធរូបអង្គថ្មីបណ្តើរ ។ បន្ទាប់មកពុទ្ធបរិស័ទសូត្រធម៌ នមស្សការព្រះរតនៈត្រ័យ ដូចទំលាប់សព្វដង ទើបសន្មតិថាចប់ ពិធីពុទ្ធាភិសេក សង្ខេបត្រឹមតែប៉ុណ្ណេះ ។

# ពិធីចំអិន និងការថ្វាយមធុបាយាស

♠ បើពុទ្ធបរិស័ទត្រូវការធ្វើពិធី ពុទ្ធាភិសេកពិស្តារ ជាពិសេសប្លែកពីពិធីដែលធ្លាប់ធ្វើរៀងមក នោះត្រូវធ្វើអស់រយៈកាល៣យប់៣ថ្ងៃគឺពីថ្ងៃ**១៤កើត ១៥កើត និងថ្ងៃ១រោច នៃខែពិសាខ** តាមទំលាប់ដែលធ្លាប់ធ្វើពីសម័យបុរាណមក ទោះបីនៅក្នុងឆ្នាំណាក៏ដោយ ។

នៅវេលារសៀលនៃថ្ងៃ១៤កើត ត្រូវរៀបចំគ្រឿងពុទ្ធបូជាចំពោះព្រះពុទ្ធរូបអង្គថ្មី ធ្វើរាជវ័តិខ្នាតតូច២ម៉ែត្រ, មាន៤ជ្រុងស្មើគ្នា នៅលើទីដីដ៏ស្អាត មិនឆ្ងាយប៉ុន្មានពីទីតំកល់ព្រះពុទ្ធរូបអង្គថ្មីនោះ ដោយមានទង់និងឆ័ត្ររួត ដែលធ្វើដោយក្រដាសពណ៌ផ្សេងៗដោតដង្ហែ ជុំវិញព្រះរាជវ័តិនោះ មានចង្ក្រានចំកណ្តាលព្រះរាជវ័តិ និងខ្ទះស្ពាន់ ឬខ្ទះដែកជំទើរមួយ និងធ្យូងសម្រាប់ដុតចំអិន មធុបាយាស កុំឱ្យមានផ្សេងដូចអុស ។

♠ នៅវេលាយប់ថ្ងៃ១៤កើតនោះ ចាប់តាំងពីម៉ោង៥ ឬម៉ោង៨ល្ងាច ទៅដល់ម៉ោង៣ជិតភ្លឺ ស្ត្រីចាស់ក្មេងច្រើននាក់ នាំគ្នាបកគ្រប់ស្រូវដំណើបឱ្យបានជាអង្ករ កុំឱ្យមានបាក់សូម្បីតែ១គ្រាប់, ឱ្យបានចំនួនល្មមដល់ការចំអិន មធុបាយាសគោក ប្រសិនបើពូតជាពំនូតៗ ឱ្យល្មមពមកើតឱ្យបាន ចំនួនគ្រប់៤៩ ពំនូត កុំឱ្យខ្វះឡើយ ។

លុះដល់វេលាម៉ោង៤ព្រឹកនៃយប់ថ្ងៃ១៤កើតនោះ ស្ត្រីទាំងអស់នាំគ្នាផ្សំគ្រឿង ដោយមានទឹកដោះគោកំប៉ុង ស្ករក្រាម ឬស្ករសក៏បាន ស្ករអំពៅបន្ទះៗក៏បាន ត្រូវយកកាំបិតស្អាតចិតឱ្យល្អិត ទឹកឃ្មុំ គ្រាប់ក្រវាញ ដែលបុកឱ្យល្អិតផង់នោះ និងផ្លែដីប្លីក្រៀម ដែលបានយកមកបុកឱ្យល្អិតផង់ដែរ (បុកហ្មត់ផង់គឺគ្រាប់ក្រវាញ និងផ្លែដីប្លីទាំង២មុខនេះ) យកតែបន្តិចៗ កុំឱ្យយកច្រើនហួសប្រមាណ មានអំបិលផង យកតែបន្តិចបានហើយ ។

ត្រូវយកគ្រឿងទាំងអស់នេះ មកផ្សំជាមួយនិងអង្ករដំណើបដែលបកហើយនោះ ដាក់ក្នុងខ្ទះ ហើយលាយទឹកឱ្យល្មមកើតជា មធុបាយាស នោះឡើងទឹកខាប់ កាលបើឆ្អិនស្រេចហើយ ឱ្យល្មមពូតជាពំនូតបាន ។ ការចំអិននេះ ត្រូវឱ្យនាងកញ្ញា២នាក់ ជាអ្នកចំអិន ឱ្យកូរបង្វិលជាទក្ខិណា គឺកូរពីស្តាំទៅខាងឆ្វេង ដូចគេដើរប្រទក្សិណអ្វីៗនោះដែរ ។

ត្រូវកូរបណ្តើរមើលភ្លើងបណ្តើរ កុំឱ្យភ្លើងដែលដុតធ្យូងនោះឆេះខ្លាំង គឺត្រូវបន្ថយភ្លើងជាដរាប ចំអិនដោយប្រុងប្រយ័ត្នជានិច្ច កុំឱ្យមធុបាយាសនោះ មានក្លិនឆ្អៀម ឬខ្លោច នៅពេលដែលកំពុងចំអិននោះឯង ត្រូវមានបុរស៤នាក់ ដែលតែងខ្លួនធ្វើជា លោកបាលមហារាជទាំង៤ដើរ ប្រទក្សិណក្រឡឹងជុំវិញព្រះរាជវ័តិ ដើរក្រឡឹងច្រើនបកច្រើនសា ត្រាតែមធុបាយាសនោះឆ្អិនស្រេចដោយប្រពៃ ។ លុះមធុបាយាសនោះឆ្អិនស្រេចហើយ នៅពេលដែលអរុណរះភ្លឺច្បាស់នៃថ្ងៃ១៥កើត ខែពិសាខនោះ នាងកញ្ញាទាំង២នាក់ ដួសដោះនូវមធុបាយាសដាក់ក្នុងចានគ្របពិសេស តំកល់ចានលើតោកទឹកមាស ឬតោកខ្យង ឬក៏ដាំកញ្ចប់ ពុំនោះទោះតំកល់លើពានជំទើរក៏បាន ប្រសិនបើមានចានមាស ឬចានប្រាក់កាឡៃមាស ក៏ជាការប្រពៃណីណាស់ សមនឹងលំអានរឿងថា " ភាជន៍មាស " ពុំចាំបាច់តំកល់លើតោកពានជំទើរឡើយ ។ នាងកញ្ញាម្នាក់ទូល **មធុបាយាស** ដើរមុនហើយសន្មតិនាងនេះថា "**នាងសុជាតា** " ជាបុត្រីនៃសេនកុដុម្ពី នៅសេនានិគម ឯនាងកញ្ញាម្នាក់ទៀតដើរពីក្រោយបន្ទាប់គ្នា ឥតទូល ឬកាន់អ្វីនោះទេ គឺសន្មតិថា **នាងបុណ្ណាទាសី** នៃនាងសុជាតា ។

កញ្ញាម្នាក់នេះដើរសំរៀមៗមិនរលះរលាំងទេ ស្ត្រីទាំងអស់ក្រៅពីកញ្ញាទាំងពីរនាក់ ដើរហែពីក្រោយ ឱ្យឃ្លាតឆ្ងាយបន្តិច ។ លុះកញ្ញាទាំង២នាក់ បានមកដល់ទីតំកល់ព្រះពុទ្ធរូបអង្គថ្មី ក៏ដាក់

មធុបាយាស ឱ្យចំចំពោះព្រះភក្ត្រព្រះពុទ្ធរូបហើយ លុតជង្គង់ក្រាបថ្វាយបង្គំហើយលើកហត្ថាប្រណម្យ បញ្ចេញវាចាថ្វាយនូវ មធុបាយាសនេះថា " **ខ្ញុំម្ចាស់ សូមថ្វាយនូវមធុបាយាសនេះ ចំពោះព្រះភគវន្ត! សូមទ្រង់មេត្តាទទួលដោយសេចក្ដីអនុគ្រោះ!** " ។

លុះដល់ពេលព្រលប់ថ្ងៃ១៥កើត ខែពិសាខ ពុទ្ធបរិស័ទត្រូវធ្វើពិធី ពុទ្ធាភិសេក តាមលំដាប់ រហូតទៅដល់អរុណោទ័យនៃថ្ងៃ១រោច ខែពិសាខ ។ នៅថ្ងៃ១រោច ខែវិសាខនោះឯង ពុទ្ធបរិស័ទត្រូវធ្វើ ពិធីឆ្លង បុណ្យពុទ្ធាភិសេក តាមការគួរដល់សទ្ធាជ្រះថ្លា ដោយការអង្គាសចង្ហាន់ពេលព្រឹក និងចង្ហាន់ ពេលថ្ងៃត្រង់ ដើម្បីប្រគេនដល់ព្រះភិក្ខុសង្ឃជាទក្ខិណាសង្ឃគតាទាន និងការនិមន្តព្រះធម្មកថិក សម្ដែងធម៌ទេសនា ក្នុងថ្ងៃនោះផងទៀតក៏បាន ។

គួរពុទ្ធមាមិកជនជ្រាបថា ពិធីបែបនេះ ពុំមែនងាយធ្វើកើតទេ បើបែរជាធ្វើកើត ក៏ជាបុណ្យ កុសលពិសេស និងគួររីករាយណាស់ ។ ប៉ុន្តែ ផ្ទុយទៅវិញ បើពុំបានគិតរិះរេឱ្យបានហ្មត់ចត់អំពី ចេតនានៃអ្នកធ្វើពិធីបែបនេះទេ ក៏បែរជារកកលនឹងយល់ឃើញថា ប្រហែលគ្នាឬដូចគ្នានឹងរឿងល្ខោន ឬក៏រឿងភាពយន្តទៅវិញទេនោះ?, ឯតាមការពិត ពុំមែនដូច្នោះឡើយ ព្រោះពិធីពុទ្ធាភិសេក បែបនេះ កើតឡើងអំពីចេតនា ជាកាមាវចរកុសលសុទ្ធសាធ បើពុទ្ធបរិស័ទអាចធ្វើបានក៏ជាការគួរធ្វើចុះ ។

ដើម្បីជាអ្នកថែរក្សាការពារនូវប្រពៃណីជាតិរបស់ខ្លួនផង និងវិស័យនៃព្រះពុទ្ធសាសនានោះ ផង ។ ហេតុនេះ បុរាណាចារ្យ បានចងក្រងឡើង ដើម្បីទុកឱ្យកុលបុត្រខ្មែរគ្រប់ជំនាន់ បានឃើញ បានយល់នូវវប្បធម៌របស់ខ្លួនពិតប្រាកដមែន ។

## សូមបញ្ជាក់ អំពីពីធី ដែលពុំគួរធ្វើ មានដូចខាងក្រោមនេះគឺៈ

១). កុំឱ្យយកកន្ត្រៃ ឬកាំបិតកោរវាស ជន្ល ហាក់ដូចជាការកាត់ព្រះកេសាព្រះ ដ្បិតព្រះពុទ្ធរូប អង្គថ្មីនោះ គឺជាងគេបានសាងរួចសព្វគ្រប់ស្រេចអស់ហើយ ។

២). កុំប្រើពិធីបើកព្រះនេត្រព្រះ ដ្បិតព្រះពុទ្ធរូបអង្គថ្មីនោះ គឺជាងគេបានសាងឱ្យមានព្រះ នេត្រទាំង២រួចស្រេចទៅហើយ ។

៣). កុំយកអំបោះចងព្រះពុទ្ធរូបចាស់ ទាញមកទាក់ភ្ជាប់នឹងព្រះពុទ្ធរូបអង្គថ្មី ដ្បិតអំបោះនោះពុំអាចស្រូបយកបារមីទានទាំង៣០ពីព្រះពុទ្ធរូបអង្គចាស់មកអង្គថ្មីនោះទេ ។ ការយល់បែបនេះ ជាទំលាប់របស់បុគ្គលខ្លះ ដែលធ្លាប់តែធ្វើខុសយ៉ាងនេះ គឺលើសពីការពិតឆ្ងាយណាស់ ពុំគួរធ្វើដូច្នេះឡើយ នាំឱ្យខាតបុណ្យកុសលខ្លួនឯងផង និងដឹកនាំអ្នកដទៃខុសទៅវិញនោះផង ។

៤). ដុតធូបថ្វាយព្រះពុទ្ធរូប ត្រូវដុតថ្វាយដោយគោរព កុំដុតឱ្យទាល់តែហុយផ្សែងទៅលើព្រះ ឬឆេះឆាបកំដៅភ្លើងទៅលើព្រះពុទ្ធរូបនោះឡើយ ។

៥). កុំឱ្យមនុស្សអ្នកក្រម៉ាច់កំប្លែង ឬមនុស្សកំពុងស្រវឹងសុរា តែងខ្លួនធ្វើជាទេវបុត្តមារ មកស្រែកគម្រាមព្រះ ដោយសម្ដែងកាយវិការ និងសំដីពុំសមរម្យ ឬមិនគោរពទៅរកព្រះឡើយ ។

៦). ពិធីណាក៏ដោយ ដទៃក្រៅពីពិធីឆ្លាំឆ្លងខាងលើនេះ ពុទ្ធបរិស័ទពុំត្រូវធ្វើពិធីនេះឡើយ ដ្បិតថា **ពុទ្ធេ អគារវតា** ប្រែថា **គឺការមិនគោរពចំពោះព្រះពុទ្ធ** ទៅវិញ ។ បើមិនគោរពចំពោះព្រះពុទ្ធហើយ ក៏ឈ្មោះថា មិនគោរពនូវព្រះធម៌ និងព្រះសង្ឃផងដែរ ហើយអ្នកដឹកនាំ ឬអ្នកធ្វើការរាជការគឺអ្នកធ្វើការធំៗ គួរយើងគោរពឱ្យសមឋានៈជាពុទ្ធសាសនិកជនផងដែរ ។

## ចប់ របៀបធ្វើពិធី បុណ្យពុទ្ធាភិសេក ប៉ុណ្ណោះ!!!

វត្តពោធិការាម នៃ ពុទ្ធិកសមាគមខេមរមណ្ឌល អូតាវ៉ា
ថ្ងៃ៥រោច ខែបុស្ស ឆ្នាំ ជូត សំរឹទ្ធិស័ក ព.ស ២៥៥២
ត្រូវនឹងថ្ងៃព្រហស្បតិ៍ទី១៥ ខែមករា ឆ្នាំ ២០០៩

ដោយ ភិក្ខុតិក្ខមុនី អ៊ុំ ឆេង,
អតីតសមណសិស្ស នៃ **ពុទ្ធិកវិទ្យាល័យ ទុតិយភូមិ អ៊ឹង ធួង** ក្រុងបាត់ដំបង ខេត្តបាត់ដំបង

ឈឈឈ ♠♠♠ ឋឋឋ

*សូមអរគុណ* !!

♠ លុះព្រះសង្ឃសូត្រចប់ហើយ ដល់ពេលភ្លឺស្រាងៗឱ្យជួសចង្ហាន់ មធុបាយាស ដាក់តំកល់នឹងភាជន៍មាស ហើយឱ្យស្រី៣នាក់ ស្លៀកហូលពាក់ស យកមធុបាយាសចូលទៅថ្វាយព្រះអង្គ ឱ្យម្នាក់ទូលចង្ហាន់ មធុបាយាស ម្នាក់ទូលគ្រឿងទឹក ម្នាក់ទូលគ្រឿងស្លា ។ លុះទូលទៅដល់មុខព្រះភក្ត្រព្រះអង្គហើយ ឱ្យលុតជង្គង់ថ្វាយបង្គំ៣ដង ហើយលើកបន្ទូលឡើង ទើបឱ្យសូត្រដូច្នេះថា៖

# នាងសុជាតា ថ្វាយមធុបាយាស ដល់ព្រះសម្ពុទ្ធ

## កំណាព្យ បទកាកគតិ

## **សម្រាប់សូត្រពេលធ្វើ បុណ្យពុទ្ធាភិសេក**

ទី១). នាងសុជាតា មានចិត្តជ្រះថ្លា ថ្វាយមធុបាយាស
ដល់ព្រះសម្ពុទ្ធ ដែលជិតបានត្រាស់ នាងអរខ្លាំងណាស់
រកអ្វីប្រៀបគ្មាន ។
នាងលុតជង្គង់ ដៃនាងកំបង់ ទ្រភាជន៍មាសមាន
ថ្វាយមធុបាយាស ដល់ព្រះទ្រង់ញាណ លាតលាឱ្យបាន
រួចចាគបំណន់ ។
រណ្ដាប់នោះណី នាងបុណ្ណាទាសី ថ្វាយឧសកៈវ៉ាទា
ទាំងគ្រឿងទិព្វតាំង អប់ទឹកកណ្ឋី នាងមានសោភី
ថ្វាយព្រះទសពល ។

ទី២). អណ្ដាប់នោះណា នាងស្រីសុជាតា ថ្វាយមធុបាយាស
សឹងគ្រឿងទិព្វគន្ធ ពេញទាំងភាជន៍មាស ទើបនាងអង្គាស
បីដងស្រេចដល់ ។
លាយបានកងចក្រ ទ្រង់ព្រះបុរសលក្ខណ៍ បញ្ចង្គអស់គល់
ស្ដេចសោយបាយាស ឥតឯសំណល់ ទើបស្ដេចតំកល់
លើកឡើងអធិដ្ឋាន ។

ទី៣). អណ្តាប់នោះណា នាងពៃសាខា ថ្វាយមធុបាយាស
សឹងគ្រឿងទន់ទិព្វ ពេញទាំងភាជន៍មាស នាងលើកអង្គាស
ថ្វាយព្រះទសពល ។

♠ សូត្រ៣ចប់ក៏បាន, មួយចប់ក៏បាន នូវកំណាព្យទាំង៣ខាងលើនេះ ហើយយកមួយណាក៏បាន ដើម្បីទៅតាមសេចក្តីត្រូវការ, រួចឱ្យលើកចូលទៅថ្វាយព្រះពុទ្ធរូបអង្គថ្មី លុះថ្វាយរួចហើយទើបឱ្យយកទឹកអប់ត្រឡប់នូវគន្ធពិដោរមកស្រង់ព្រះអង្គ កាលនឹងស្រង់នោះឱ្យសូត្រដូច្នេះថា៖ **តេ ពុទ្ធាទនានេ នមោ ឥន្ទំ ន មឃំ ហោហិ** (សូត្រ៣ចប់ហើយស្រង់ព្រះទៅហោង) ។ លុះស្រង់រួចស្រេចហើយ កាលណា ទើបព្រះអង្គឆាន់នូវចង្ហាន់ **មធុបាយាស** អស់សំណល់ បរិបូណ៌ស្កប់ស្កល់ ដល់កាលត្រាស់នោះណា ដូចមានកំណាព្យសម្រាប់សូត្រខាងក្រោមនេះគឺ៖

ទី៤). ព្រះអង្គបានស្រេច ក្សិណនោះសារពេជ្រ បានត្រាស់ប្រាជ្ញា
ផុសរត្នបល្ល័ង្ក ទែនទាំងសុវណ្ណា សឹងរត្នវេគ្វា
កើតដោយបារមី ។
ទើបពោធិព្រឹក្ស លំពង់លាស់ស្លឹក ពណ៌ស្រស់ខៀវខ្ចី
ក្រោយរត្នបល្ល័ង្ក បាំងព្រះជិនស្រី ពន្លឺរស្មី
រន្ទាលទែងទុំ ។

កំណាព្យទី៤នេះ បុរាណាចារ្យលោកឱ្យសូត្រតែមួយចប់ជាការស្រេច លុះសូត្រចប់ហើយទើបសូត្រកំណាព្យមួយទៀតគឺ បទុមថ្វាយផ្កាឈូក បើគ្មានផ្កាឈូក ឬផ្កាម្លិះក៏បានដែរ ព្រោះគិតទៅតាមស្រុក ប្រទេស, ប្រសិនបើនៅក្នុងប្រទេសកម្ពុជាគឺមានផ្កាឈូកជាច្រើន និងពេលវេលាក៏ច្រើនផងដែរ, ចំណែក ឯពុទ្ធបរិស័ទ ដែលបានរស់នៅបរទេស ក្រៅពីកម្ពុជាគឺថាមិនមានពេលវេលាធ្វើដូចនៅស្រុកខ្មែរនោះទេ គ្រាន់តែបានធ្វើពិធីសង្ខេបប៉ុណ្ណោះ ដូចជានៅក្នុងប្រទេស **កាណាដា** ជាដើម ។

ដោយយល់ឃើញថា របៀបធ្វើបុណ្យពុទ្ធាភិសេក មានសភាពអស្ចារ្យ ទើបប្រមូលរៀបរៀងឡើង ដើម្បីចែកជូនដល់ពុទ្ធបរិស័ទទូទៅ គ្រាន់បានដឹង បានយល់ ព្រោះនូវក្នុងអត្ថបទនេះ មានកំណាព្យ សម្រាប់សូត្រ ដោយមានវគ្គឃ្លាត្រឹមត្រូវទៅតាមលំដាប់បទនីមួយៗ ។

អាស្រ័យដូចបានរៀបរាប់មកនេះ សូមកវីបណ្ឌិតទាំងឡាយ មេត្តាជួយកែសម្រួលឱ្យមានរសធម៌ដ៏ឧត្តម និងមានសុពលភាពជាងនេះ ។

# បទបទុម ថ្វាយផ្កាឈូក សូត្របែបលំនាំបុរាណ

## សម្រាប់សូត្រពេលធ្វើ បុណ្យពុទ្ធាភិសេក

**កំណាព្យ បទព្រហ្មគីតិ**

ទី៥). បទុមក្រពុំរីក មានចិត្តត្រេកកាច់មកថ្វាយ
បទុមក្រពុំចាយ កាច់មកថ្វាយកបកេសរ ។
បទុមក្រពុំល្អ កបកេសរបទុមវ័ត្ន
វន្ទាបង្អោនអង្គ លើកំបង់ទាំងគូរគ្រប់ ។
ម្រាមដៃខ្ញុំទាំងដប់ បបោសច្រឹបនូវក្រចក
បីដូចវាល់ត្របក កេសរផ្កាឈូកក្រពុំ ។
យើងខ្ញុំទាំងអស់គ្នា លើកហត្ថាថ្វាយបង្គំ
កេសរនឹងបទុម ថ្វាយបង្គំព្រះជិនស្រី ។

ទី៦). បទុមក្រពុំរីក មានចិត្តត្រេកកាច់មកថ្វាយ
បទុមក្រពុំសាយ បង្កាច់កាយកបកេសរ ។
លុតលើកទាំងទស្សករ ប្រណម្យដោមលើសិរសី
បង្គំគុណកែវបី ខ្ពស់លើសលុបត្រៃលោកា ។

ក្នុងបទទី៥នឹងទី៦នេះ សម្រេចទៅលើអ្នកសូត្រយកមួយណាក៏បាន តាមតែចំណង់របស់អ្នកសូត្រ ហើយបុរាណាចារ្យលោកឱ្យសូត្រតែមួយចប់ជាការស្រេច ។

## សម្រាប់សូត្រក្នុងពិធីធ្វើ បុណ្យពុទ្ធាភិសេក

## កំណាព្យបុរាណ បទកាកគតិ

**បទផ្ចាញ់មារ កាលព្រះអង្គចេញសាងបព្វជ្ជា**

ទី៧). នាកាលអធ្រាត្រ ស្តេចនឹកអនាថ អាណិតឥតស្បើយ
ទ្រង់ស្រែកផ្តាំថា កុមារកូនអើយ ឪពុកលាហើយ
យាត្រាទៅបួស ។
អ្នកនៅនឹងម្តាយ ឱ្យសុខសប្បាយ កុំបីមានមោះ

| | | |
|---|---|---|
| រោគាព្យាធិ | អ្វីបន្តិចសោះ | កុំឱ្យមានមោះ |
| | ដល់កូនពុំងា ។ | |
| ទ្រង់បរសេះទៅ | ហើយកាត់សំដៅ | ទៅឯក្លោងទ្វារ |
| ទេវតាបើកស្រាប់ | សម្រាប់រាជា | ស្តេចដល់ក្លោងទ្វារ |
| | ស្រែផ្តាំកូនថា ។ | |
| រាហុលកូនប្រុស | នៅនឹងម្តាយចុះ | ឱ្យបានសុខា |
| កុំឱ្យមានរោគ | អ្វីមកពាធា | បិតាសូមលា |
| | ទៅបព្វជ្ជាហើយ ។ | |
| ឱ!ប្រុសពន្លក | អ្នកទើបកើតមក | ថ្ងៃនេះកូនអើយ |
| មិនសមបិតា | យាត្រាចោលឡើយ | គួរនៅកៀកកើយ |
| | រក្សាបុត្រភ្វា ។ | |
| ឥឡូវបិតា | មកនេះប្រាថ្នា | នឹងបុត្រពុំងា |
| ក្រសោបឱបបី | បបោសអង្គា | រួចហើនឹងលា |
| | ទៅបព្វជ្ជាណា ។ | |
| ឥឡូវម្តាយអ្នក | លើកហត្ថម្ខាងដាក់ | ពាក់លើឱរា |
| ហត្ថម្ខាងធ្វើខ្នើយ | ឱ្យអ្នកកើយណា | គ្រានោះបិតា |
| | ខុសអាជ្ញាហើយ ។ | |
| | **ចប់កំណាព្យទី៧** | |

# កាលព្រះអង្គទ្រង់ផ្ចាញ់មារ

## កំណាព្យបុរាណ បទពាក្យ៧

ទី៨). ថ្លែងកាលសម្តេចព្រះគោត្តម ខិតខំបំពេញព្រះបារមី
ទុក្ករកិរិយាដោយឃ្មាតខ្មី ដើម្បីបានត្រាស់ពោធិញ្ញាណ ។
អស់ពេលវេលាប្រាំមួយឆ្នាំ អត់ធ្មត់ស៊ូទ្រាំដោយក្លាហាន
ក៏មិនសម្រេចពោធិញ្ញាណ ទើបបានពិនិត្យគិតជាថ្មី ។
ទ្រង់យល់ថាការកាន់តឹងហួស ជ្រលួសហេតុផលជាប្រក្រតី
មិនអាចសម្រេចប្រយោជន៍អ្វី ឱ្យបានតែក្តីទុក្ខវេទនា ។
ដូចជាចាប៉ីរឹតខ្សែតឹង នាំឱ្យដាច់ភឹងមិនបានការ

តែបើធូរពេកហួសធម្មតា ក៏មិនបានការដូចគ្នានៃ ។
ផ្លូវល្អគឺផ្លូវជាកណ្តាល មិនធូន់មិនស្រាលគឺល្មមលៃ
អាត្មាគួរផ្លាស់ផ្លូវទីទៃ គឺផ្លូវល្មមលៃប្រពៃពិត ។
ទុក្ករកិរិយាតឹងតែងណាស់ មិនឃើញបានត្រាស់ធម៌ពិសិដ្ឋ
យល់យ៉ាងនេះហើយព្រះវិចិត្រ ក៏ឈប់ប្រព្រឹត្តទុក្ករកម្ម ។
ទ្រង់យាងបិណ្ឌបាត្រដូចសព្វកាល កាន់ផ្លូវកណ្តាលយ៉ាងមធ្យម
មានព្រះពលកាយល្អឧត្តម សម្ងំហាត់ចិត្តពិនិត្យធម៌ ។
ក្រោយពីឆាន់មធុបាយាស ចង្ហាន់វិសេសវិសិដ្ឋល្អ
នាងសុជាតាថ្វាយភូធរ ស្តេចចរមកដើមពោធិព្រឹក្ស ។
ថ្ងៃ១៥កើតខ្ទើតបុណ្ណមី វិសាខមាសីនក្ខត្តឫក្ស
ថ្ងៃពុធឆ្នាំវកព្រះធម្មិក ស្ញឹងស្មាធិរំលឹកកម្មដ្ឋាន ។
លើព្រះរតនៈបល្ល័ង្ក រំលេចក្បាច់ចាំងល្អចំណាន
ផុសឡើងទទួលព្រះទ្រង់ញាណ ឱ្យបានគង់ត្រាស់ព្រះធម៌ថ្លៃ ។
ទ្រង់តាំងអធិដ្ឋានដាច់ស្រេច បើមិនសម្រេចព្រះញាណញេយ្យ
នឹងមិនដកភ្នែនពែននេះនៃ ហើយទ្រង់រំពៃរំពឹងធម៌ ។
ពួកទេពនិករអមរមេឃ ច្រើនក្រៃអនេកសឹងត្រេកអរ
បាចសាចផ្កាភ្ញីថ្វាយភូធរ ស្រែកថ្វាយពរជ័យគ្រប់ៗគ្នា ។
កាលនោះក្រុងមារាធិរាជ គំនិតកំណាចកាចមហិមា
ដឹងច្បាស់ថាអង្គព្រះសម្មា ទើបភ្ញុំសេនាពលទាហាន ។
សុទ្ធតែប្រដាប់ដោយអាវុធ ចិត្តមុតអង់អាចនិងក្លាហា
មកជួបជុំគ្នារាប់កោដិលាន និម្មិតក្លែងប្រាណគ្រប់ៗគ្នា ។
ឯអង្គមារាជាចមពល យង់យល់សកលពលយោធា
មកជួបជុំគ្នាហើយទើបអាត្មា លីលាគង់លើគជេន្ទជ័យ ។
កំពស់មួយរយហាសិបយោជន៍ លន្លោចដល់នានភាល័យ
ឈ្មោះគ្រីមេខលស្គាល់ស្ពឹមស្តៃ ធំក្រៃសម្បើមឆ្នើមកុញ្ជរ ។
ហត្ថាមួយពាន់កាន់អាវុធ គ្រឿងយុទ្ធកៅទណ្ឌនឹងធ្នូសរ
សន្ធាប់ប្រាមប្រាប់ពលនិករ ចូរយើងចេញចរប្រញាប់វៃ ។
តែយើងកុំទៅចំពីមុខ ត្រូវលុកពីក្រោយស្រួលវិលវៃ

ព្រោះព្រះសិទ្ធត្ថមានបុណ្យក្រៃ យើងត្រូវលកលៃចាប់ឱ្យបាន ។
ពលមារកាលទើបទៅទៀបជិត បែរជាភ័យភិតមិនក្លាហាន
ទោះមារបង្ខំអម្បាលមាណ ក៏នៅមិនហ៊ានចិត្តរុញរា ។
មារាធិរាជខឹងពេកណាស់ សម្តែងតេជៈឫទ្ធិនានា
បណ្តាលជាភ្លៀងអាវុធា ជាខ្យល់ជាភ្លៀងជារន្ទះ ។
តែមិនអាចធ្វើពោធិសត្វ ឱ្យជួបវិបត្តិវិប្បល្លាស
អាវុធទាំងនោះប្រែក្រឡាស់ ក្លាយផ្លាស់ជាភ្ញីផ្កានានា ។
វេទមន្តយន្តយុទ្ធអាវុធសព្វ ត្រឡប់ប្រែជាគ្រឿងបូជា
យក្សអស់ចំណេះចង់រុញរា ក្រោយវាមូម៉ៅក្តៅក្រហាយ ។
ទើបស្រែកគំរោះទ្រគោះស្តី នែវ៉ឺយសិទ្ធត្ថចេញឱ្យឆ្ងាយ
បើរឹងទទឹងនឹងអន្តរាយ ជីវិតរូបកាយវិនាសពិត ។
ចុះពីលើបល្ល័ង្ករតន៍ឆាប់ៗ បល្ល័ង្កជាទ្រព្យយើងស័ក្តិសិទ្ធិ
ម្តេចក៏ចោរក្បត់អត់គំនិត មិនគិតអៀនខ្មាសបន្តិចសោះ ។
ធម្មិកទ្រង់ឆ្លើយដោយមេត្រី វចីវាចាមិនខ្វះខ្មោះ
បន្ទូលភរម្យសមពិរោះ ចំពោះក្រុងមារអសុរី ។
ខ្លួនយើងកសាងស្អាងចរិយា អាសនាកើតឡើងដោយបារមី
អ្នកពោលដូច្នោះខុសសេចក្តី ឯណាសាក្សីដឹងឮផង ។
ទើបមារឆ្លើយតបកបវាទី នេះនៃសោធីច្រើនកន្លង
សុទ្ធសឹងដឹងឮច្បាស់ម៉ដ្ឋហ្មង ពលមារវ៉ាប់រងរាល់កាយា ។
យើងខ្ញុំដឹងពិតសព្វសេចក្តី វសៈវតីបារមីក្លា
បល្ល័ង្កកើតឡើងដល់ក្សត្រា សម្រាប់ចេស្តាទ្រង់សួស្តី ។
មារមានឱកាសឆ្លាស់ឆ្លងឆ្លើយ អ្នកអើយមិនឮឬសាក្សី
គេឆ្លើយត្រូវការទាំងផែនដី ខ្លួនអ្នកបានអ្វីជាបន្ទាល់ ។
ឯអង្គពង្សជាតិព្រះមុនី យកប្រឹថពីជាសំគាល់
បុណ្យដែលយើងសាងសំអាងផ្ទាល់ ផែនដីដឹងស្គាល់រាល់ៗគ្នា ។
កាលនោះផែនដីញ័រកក្រើក ស្ទើរហាក់របើកទាំងមេឃា
ទូលទាស់តបស្នងសងវាចា ធានាជាស្មរត៍សេចក្តី ។
ខ្ញុំបានចាំជាក់ព្រះចក្រពង្ស កាលទ្រង់កសាងស្អាងបារមី

បល្ល័ង្កទើបកើតឡើងថ្មីៗ សម្រាប់ចក្រីគង់ត្រាស់ដឹង ។
ពលមារភ្ញាភ្ញាក់ធ្លាក់ហប្ញទ័យ ភិតភ័យតោឡោភ្នែកស្លោស្លឹង
មិនអាចទទឹងរឹងរបឹង សំឡឹងមើលច្រកកបដោះដៃ ។
មុខចំខាងណាទៅខាងនោះ សំរុកដូចព្យុះសូរខ្លាំងក្រៃ
កម្លាំងប៉ុន្មានគ្មានសំចៃ អាល័យរូបកាយស្តាយជីវី ។
ខ្លះរត់ផុតធ្លាពារព្រៃធំ រលំរឹលរេចបាក់ខ្ទេចខ្ទី
វង្វេងព្រាយព្រាត់បាត់គ្នាគ្នី រកទីពឹងពួនសួនអាត្មា ។
មារារឹងរឹទ្ធិចិត្តកំហល់ លុះដល់បាក់ទ័ពអបរា
ភ័យក្លាចអំណាចព្រះចេស្តា ហត្ថាលំទោនឱនសិរសី ។
បង្គំសូមទោសទូលសរសើរ ដំណើររ៉ាយរាប់ប្រៀបសេចក្តី
ព្រះអង្គជាម្លប់ភពទាំងបី រកអ្វីប្រៀបផ្ទឹមត្រឹមស្មើគ្មាន ។
ជាវង្សពង្សពុទ្ធផុតភពភារ ផ្ចាញ់មារបាក់បបកបញ្ញេយ្យញាណ
នាំសត្វសាកលដល់និព្វាន លែងមានទោសទុក្ខសែនសុខា ។
លុះពោលបញ្ចប់សព្វសេចក្តី អសុរីលុតលាហើយយាត្រា
ឆ្ពោះទៅលំនៅនៃអាត្មា ចិន្តាកើតទុក្ខមុខម្ញូហ្មង ។
ឯហ្វូងទេវតាកោលាហល ច្របល់ភ្លូកភ្លឹករត់គឹកកង
ចោលព្រះមុនិន្ទពិនច្បាស់ច្បង ត្រសងឈរមើលពីចំងាយ ។
បានយល់ពលមារម្ទីម្នារត់ ភ័យញ័ររន្ធត់រត់ខ្វាត់ខ្វាយ
ត្រេកអរក្សេមក្សាន្តបានសប្បាយ លំឱនកាយថ្វាយសាធុការ ។
រឿងមារវិជ័យខ្លីសង្ខេប ខ្ញុំសូត្រជាបែបបទធម្មតា
ចែកជូនលោកអ្នកសវនា នាំកើតជ្រះថ្លាក្នុងសន្តាន ។
បញ្ចប់ប៉ុណ្ណេះស្លេះសេចក្តី សូមសុខសួស្តីចូរកើតមាន
ដល់លោកអ្នកស្តាប់គ្រប់ៗប្រាណ សូមសុខក្សេមក្សាន្តនិព្វានហោង ។

**ចប់ បទផ្ចាញ់មារ!!!**

**ꕥꕥꕥ♠♠♠ꕥꕥꕥ**

ពុទ្ធិកសមាគមខេមរមណ្ឌល អូតាវ៉ា
Bodhikaram Temple, 1197 Deer Park Road, Ottawa, ON, K2E 6H5
www.bodhikaram.com